# ប្លង់មេរៀនស្តីអំពីសេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ

# ចំនួន ៤៥ ម៉ោង

## សេចក្តីផ្តើម :

ជាការពិតសព្វថ្ងៃសភាពការណ៍កម្ពុជា និង ស្ថានភាពនយោបាយជាបញ្ហាមួយដ៏សំខាន់ ដែលអ្នកវិទ្យាសាស្ត្រកំពុងតែយកចិត្តទុកដាក់ ។ រលកមនោគមន៍វិជ្ជា និង នយោបាយដឹកនាំនៃប្រវត្តិសាស្ត្រកន្លងមកបាន បន្សល់ទុកឱ្យប្រជាជនកម្ពុជា នូវការរងទុក្ខវេទនា ខ្លោចផ្សា ប្តីព្រាត់ប្រាស់ប្រពន្ធ ព្រាត់ប្រាស់គ្រួសារ ព្រាត់ប្រាស់កូន ចំណែកឯកូនព្រាត់ប្រាស់ ឪពុកម្តាយ កំព្រាអនាថារាប់ម៉ឺននាក់ ។ ឥទ្ធិពលនយោបាយនៃមជ្ឈដ្ឋានទាំងក្នុង និង ក្រៅប្រទេស ទោះក្នុងទ្រង់ទ្រាយ ជាស្មារតីក្តី ឬ ជាសំភារៈក្តី គឺសុទ្ធតែជាថ្នាំបំពុល ធ្វើឱ្យស្មារតីខ្មែរធ្លាក់ចុះ បាត់បង់ម្ចាស់ការ ធុញទ្រាន់និងនយោបាយ ហើយធ្វើឱ្យស្អប់ខ្ពើមអ្នកនយោបាយ។ ជាការពិតមកដល់សព្វថ្ងៃនេះ ពិបាកនឹងនិយាយថា ប្រជាជនកម្ពុជាមានកំរិត យល់ដឹងខ្ពស់ខាងផ្នែកពុទ្ធិនយោបាយ និង វិទ្យាសាស្ត្រនយោបាយ។ លទ្ធផលបែបនេះធ្វើឱ្យ ប្រជាជនកម្ពុជាមានទីតាំង ត្រឹមតែជាវត្ថុវិស័យភាពនៃនយោបាយតែប៉ុណ្ណោះ។

## គោលបំណងនៃការសិក្សា

ចំណុចសំខាន់ដែលប្រធានបទនេះចង់បញ្ជាក់នោះគឺ តើប្រជាជនកម្ពុជាយល់យ៉ាងណាចំពោះបញ្ញត្តិនយោបាយ តើប្រជាជនកម្ពុជាមានតួនាទី ឬ ទីតាំងបែបណាក្នុងនយោបាយ ? តើប្រជាជនកម្ពុជាអាចមិនធ្វើនយោបាយបានដែរឬទេ? តើប្រជាជនកម្ពុជាអាចមិនចូលរួមក្នុងការងារនយោបាយបានដែរឬទេ?

ម៉្យាងវិញទៀត ដោយសារតែមានការសិក្សាទៅលើបញ្ហានយោបាយ អាចជួយឱ្យអ្នកសិក្សា ចេះពិចារណា និង ស្គាល់គន្លឹះនៃបញ្ហាជំលោះដែលតែងតែកើតមានក្នុងសកម្មភាពនយោបាយ ថែមទាំងការស្គាល់ពីមូលដ្ឋាននៃ គំនិតនយោបាយខុសៗគ្នាដែលកំពុងមានអត្ថិភាពក្នុងសង្គម អាចជួយឱ្យយើងមានលទ្ធភាពក្នុងការធ្វើវិភាគ និង ចូលខ្លួនយ៉ាងជ្រៅ ស្គាល់នូវបាតុភូត និង សារជាតិពិតរបស់នយោបាយ ហើយដែលជួយចង្អុលបង្ហាញនូវលទ្ធភាព ដោះស្រាយបញ្ហាទាំងនោះបានសមស្របទៅនឹងតំរូវការ ជាក់ស្តែងសំរាប់ជាប្រយោជន៍ដល់សង្គម។

## ជំពូកទី ១ ៖ វិទ្យាសាស្ត្រនយោបាយ ៦ម៉ោង

វិទ្យាសាស្ត្រនយោបាយ ពន្យល់ច្បាស់លាស់អំពីនយោបាយ ។ មិនតែប៉ុណ្ណោះ វាសិក្សា អំពីទំនាក់ទំនងទៅវិញទៅមកនៃវប្បធម៌ និង អរិយធម៌របស់មនុស្ស។

### អ្វីទៅជានយោបាយ

ពាក្យនយោបាយមានន័យច្រើនយ៉ាងទៅតាមការយល់ឃើញរបស់អ្នកប្រាជ្ញម្នាក់ៗ។ តាមភាសាក្រិចពាក្យនយោបាយស្មើពាក្យ **Politika** មានន័យថា កិច្ចការទំនាក់ទំនងរបស **Politikos**ក្នុងសង្គម រឺ កិច្ចការទំនាក់ទំនងទំនងរបស់**Politikos**ក្នុង **Polis** ចំណែកឯពាក្យ **Polis** = បុរីរដ្ឋ ។ តាមទស្សនៈប្លាតុង បានឱ្យនិយមន័យថា "នយោបាយគឺជាសិល្បៈដឹកនាំមនុស្សឱ្យមានការ យល់ព្រម សុខចិត្តសុខកាយ "។ តាម Niccolo Machiavlli ថា "នយោបាយ គ្មានអ្វីក្រៅពីការតស៊ូដើម្បីអំណាចតែ ប៉ុណ្ណោះ។ មនុស្សស្រេកឃ្លានអំណាច ហើយកាលណាគេបានអំណាច ហើយគេ តែងតែចង់បានអំណាចនោះទៀតមិនលែង"។ តាមទស្សនៈរបស់លេនីន ថា" នយោបាយ គឺជាការប្រលូកនៅក្នុងកិច្ចការរបស់រដ្ឋ គឺជាការកំណត់ទិសដៅដឹកនាំ រដ្ឋ ឬ ជាការកំណត់ទិសដៅលើទំរង់ការកំណត់បញ្ហារដ្ឋ និង ការបីបាច់ថែរក្សាកិច្ចការរបស់រដ្ឋ "។ អារីស្តូត ជាបិតានៃវិទ្យាសាស្ត្រនយោបាយបានពោលថា " នយោបាយជាវិទ្យាសាស្ត្រស្តីពីភាពថ្កុំថ្កើនភាពសំបូរសប្បាយរបស់មនុស្ស និង បុរីរដ្ឋទាំងអស់"។ Montesquieu បានសាកល្បងឱ្យនិយមន័យលើពាក្យនយោបាយ ដោយធ្វើការកត់សំគាល់ទៅលើមុខងាររបស់រដ្ឋាភិបាលដែលមានទំនាក់ទំនងទៅនឹងច្បាប់ទាំងក្នុងអង្គនិតិបញ្ញត្តិ និតិប្រតិបត្តិ និង និតិតុលាការ។ Jean Bodin ជាមនុស្សវិទូបារាំង និង ជាអ្នកច្បាប់បានកំណត់ន័យថា នយោបាយជាការរៀបចំនៃស្ថាប័ននានាក្នុងទំនាក់ទំនងជាមួយច្បាប់។ ម៉្យាងវិញទៀត ដោយសារតែមានការសិក្សាទៅលើបញ្ហានយោបាយ អាចជួយឱ្យអ្នកសិក្សាចេះពិចារណា និង ស្គាល់គន្លឹះនៃបញ្ហាជំលោះដែលតែងតែកើតមានក្នុងសកម្មភាពនយោបាយថៃមទាំង ការស្គាល់ពីមូលដ្ឋាននៃគំនិតនយោបាយខុសៗគ្នា ដែលកំពុងមានអត្ថិភាពក្នុងសង្គម អាចជួយឱ្យយើងមានលទ្ធភាពក្នុងការធ្វើវិភាគ និង ចូលខ្លួនយ៉ាងជ្រៅដើម្បីបានស្គាល់បាតុភូត និង សារជាតិពិតរបស់នយោបាយ ហើយដែលជួយចង្អុលបង្ហាញនូវលទ្ធភាពដោះស្រាយបញ្ហាទាំងនោះ បានសមស្របទៅនឹងតំរូវការជាក់ស្តែងរបស់សង្គម។

## ជំពូកទី ២ ៖ ស្ថិរភាពនយោបាយ ៦ម៉ោង

ដើម្បីធ្វើឱ្យនយោបាយមានស្ថិរភាព គឺជាមុខងារដ៏សំខាន់ហើយចាំបាច់បំផុតរបស់ស្ថាប័ននយោបាយ។ ក្នុងករណីកិច្ចនេះចាំបាច់ត្រូវប្រើនូវយន្តការនយោបាយផ្សេងៗ។ ឧ: យន្តការខ្លះដូចជា ការចុះកិច្ចព្រមព្រាងជា

មួយបណ្តាគណៈបក្ស នយោបាយទាំងបួននា ថ្ងៃ ២៣ខែតុលាឆ្នាំ ១៩៩១ នៅទីក្រុងបារីស ធ្វើឡើង ដើម្បីផ្តល់ឱ្យសង្គមនូវសន្តិសុខនិងភាពស្ងៀមស្ងាត់ក្នុងប្រទេស។ បញ្ហាស្ថិរភាព និង អស្ថិរភាពបានកើតមាន ឡើងនឹងកំពុង តែកើតមានឡើងហើយនឹង កើតមានឡើងពោលគឺបញ្ហាមានភាពអមតៈ។

## ជំពូកទី ៣ : ប្រពន្ធ័នយោបាយ ៦ ម៉ោង

អ្នកប្រាជ្ញជាច្រើនបានពន្យល់អត្ថន័យប្រព័ន្ធនយោបាយខុស១គ្នា។ ប្រព័ន្ធនយោបាយគឺជាកិច្ចការ ទំនាក់ទំនងរវាង ស្ថាប័ននយោបាយ ចំរុះផ្សេង១គ្នា មានលក្ខណៈស្មុគ្រស្មាញ ជាសមាគមន៏នយោបាយសង្គម ដែលមានរចនាសម្ព័ន្ធពាក់ព័ន្ធគ្នា នឹង អំពើទៅវិញទៅមករវាងអង្គរទាំងអស់នោះ ដែលទាំងអស់នេះបង្កើតឱ្យមានសកម្មភាពក្នុងការសំរេចអំណាចនយោបាយ។ វិទ្យាសាស្ត្រនយោបាយនៅលោកខាងលិចយើងអាចទាញយកនិយមន័យ មួយស្តីអំពីប្រព័ន្ធនយោបាយ គឺជាទំនាក់ទំនង រវាងពួកអេលីត ដែលមានឋានានុក្រម និង ពលរដ្ឋ ក្នុងនោះអេលីតដើរតួរជាអ្នកគ្រប់គ្រង ចំណែកពលរដ្ឋវិញជាក្រុមត្រូវបានគេគ្រប់គ្រង។ ចេញពីទីនេះត្រូវតែកត់ចំណាំថានិយមន័យនេះក៏ដូចជានិយមន័យផ្សេងទៀតជាច្រើនដែរបានត្រូវកំនត់ដោយច្បាប់នៃប្រព័ន្ធនយោបាយ ទាមទារឱ្យគោរពតាម។

## ជំពូកទី ៤ : ការចូលរួមក្នុងកិច្ចការនយោបាយ ៦ ម៉ោង

ការចូលរួមនៅក្នុងសកម្មភាពនយោបាយ គឺជាអំពើដែលត្រូវបានកំនត់ដោយផ្ទាល់របស់បុគ្គលដើម្បីទាមទារឱ្យបាននូវទិសដៅរបស់ខ្លួនដោយប្រើនូវសិទ្ធិសេរីភាពប្រើការយល់ដឹងនូវស្ថានភាពសង្គមប្រើលទ្ធភាព និង សមត្ថភាព។ ដោយសារតែមានការចូលរួមក្នុងសកម្មភាពនយោបាយពីសំណាក់បុគ្គល ទីបំផុតបានបង្ហាញឱ្យឃើញថា : សមិទ្ធិផលដែលទទួលបាននៅក្នុងវិស័យនយោបាយ មានលទ្ធភាពមិនមែនបំរើតែផលប្រយោជន៏ចំពោះពួកក្រុមធំ១ នៅក្នុងសង្គមនោះទេ ប៉ុន្តែក៏ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ទុរគតិជន ឬ មនុស្ស សាមញ្ញ និង ប្រជាជនទូទៅផងដែរ។

## ជំពូកទី ៥ : នយោបាយ និង សេដ្ឋកិច្ច ៦ ម៉ោង

ការធ្វើសកម្មភាពរួមនៃនយោបាយ និង សេដ្ឋកិច្ច មានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរអភិវឌ្ឍន៏នៃសង្គម។ អ្នកនយោបាយសម្របសម្រួលទំនាក់ទំនងសេដ្ឋកិច្ច ផលប្រយោជន៏សេដ្ឋកិច្ច។ នៅពេលនោះដែរ នៅពេលដែលពង្រីកទំហំវិស័យសេដ្ឋកិច្ចឱ្យបានធំភាពស្មុគស្មាញទំនាក់ទំនងសេដ្ឋកិច្ចនៅក្នុងសង្គមកាន់តែកើនឡើងដែរ សកម្មភាពនយោបាយនៅក្នុង វិស័យសេដ្ឋកិច្ច គឺជាកត្តាចាំបាច់។ ភាពជំមុតស្រួចនៅក្នុងទំនាក់ទំនងនយោបាយ និង សេដ្ឋកិច្ចកើតឡើងនៅពេលដែល កើតឡើងនូវការបាក់បែកយ៉ាងខ្លាំង នៅក្នុងទំនាក់ទំនងសង្គម រចនាសម្ព័ន្ធសង្គមដែលផ្តល់ និង

វាយតំលៃចំពោះការយល់ដឹង អំពីសង្គម។ សង្គមយើងសព្វថ្ងៃ ស្ថិតនៅក្នុងស្ថានភាពមួយដែលកម្លាំងសង្គម និង នយោបាយផ្សេងៗកំពុងតែស្វែងរកមាគ៌ា ដើម្បីសិក្សា និង រៀបគំរោងទស្សនៈទានណាមួយដើម្បីចេញពីវិបត្តិ។

## ជំពូកទី ៦ : នយោបាយ និង សាសនា ៣ ម៉ោង

សាសនា គឺជាផ្នែកមួយនៃវប្បធម៌មនុស្ស ដែលរស់នៅលើលោកយើងនេះ។ ហេតុដូច្នេះហើយ រាល់ការប្រឹងប្រែង ដើម្បីប្រឆាំងនឹងសាសនា ទីបំផុតជួបប្រទះនឹងការរលំរលាយ។ នៅក្នុងអតីតកាល នៅក្នុងប្រទេសសង្គមនិយម មានគំនិតមួយគ្របសង្កត់ពីលើសាសនា ហើយយល់ថាគ្មានទីកន្លែងនៅក្នុងរង្វង់នៃប្រព័ន្ធនយោបាយសង្គមទេ។ ដូចបានដឹង ហើយថា លទ្ធិម៉ាក្ស គឺជា សត្រូវនឹងសាសនា។ នៅក្នុងទំនាក់ទំនងនេះ បានធ្វើឱ្យទំនាក់ទំនងរវាងសាសនា និង នយោបាយ មិនស្ថិតស្ថេរទេ។ ប៉ុន្តែសព្វថ្ងៃនេះ ស្ថានការណ៍ត្រូវបានប្រែប្រួលទាំងស្រុង។

## ជំពូកទី ៧ : នយោបាយ និង ការគ្រប់គ្រង ៣ ម៉ោង

ក្នុងការសិក្សាទំនាក់ទំនងរវាងរបបនយោបាយជាមួយនឹងរបបគ្រប់គ្រង អាចមានគំនិតជាច្រើនដែលខុសប្លែកគ្នា តែនៅក្នុងរដ្ឋបាលសាធារណៈមានគំនិតមួយសួថា តើគួរបំបែកនយោបាយចេញពីការគ្រប់គ្រងបានដែរឬទេ? ទោះជាក្នុងភាពជាក់ស្តែងរបបនយោបាយ និង របប គ្រប់គ្រងមានដំណើរជាប់ជាមួយគ្នារហូតមក ដោយរបបគ្រប់គ្រងជាផ្នែកមួយនៃរបបនយោបាយ តែដោយមកពីរបប នយោបាយមានឥទ្ធិពល និង តួនាទីច្រើនលើរបបគ្រប់គ្រងបានធ្វើឱ្យអ្នកសិក្សាមួយក្រុមគិតឃើញថា ដើម្បីជាប្រយោជន៍ ក្នុងការវិវត្តន៍របបគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធិភាពគួរបំបែកនយោបាយចេញពីការគ្រប់គ្រងឱ្យបានច្បាស់លាស់ដោយ មានលោក Woodrow Wilson ជាអ្នកដឹកនាំក្នុងការគិតគួរបញ្ហានេះ ឃើញថាគួរ បំបែកនយោបាយចេញពីការ គ្រប់គ្រងឱ្យបានច្បាស់លាស់ ព្រោះថាដោយផ្អែកលើលក្ខការណ៍របបនយោបាយមាន តួនាទីបញ្ញត្តិច្បាប់ និង កំណត់ នយោបាយសាធារណៈ ក្នុងពេលដែលរបបគ្រប់គ្រងមានតួនាទីក្នុងការនាំនយោបាយ ទៅប្រតិបត្តិឱ្យបានសំរេចទៅតាម គោលដៅ ហើយដើម្បីជំរុញការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធិភាពគួរតែអភិវឌ្ឍន៍ របបគ្រប់គ្រងរដ្ឋបាលឱ្យមានលក្ខណៈ ដូចគ្នានឹងការគ្រប់គ្រងធុរៈកិច្ចទាំងនេះ ព្រោះលោក Wilson ឃើញថាការ គ្រប់គ្រងធុរៈកិច្ចមានប្រសិទ្ធិភាពជាងការ គ្រប់គ្រងរដ្ឋបាល។

## ជំពូកទី ៨ : មេដឹកនាំនយោបាយ ៦ ម៉ោង

មេដឹកនាំប្រើជាភាសារអង់គ្លេស (Leader) បានន័យថា អ្នកគ្រប់គ្រង ឬ អ្នកដឹកនាំផ្លូវ។ អត្ថន័យពាក្យនេះបានឆ្លុះ បញ្ចាំងពីសកម្មភាពរបស់មេដឹកនាំក្រុមមនុស្ស, ឆ្លុះបញ្ចាំងពីមុខងារ, តួនាទី, ទីកន្លែង និង រាល់សកម្មភាព

ដែលគេបានចូលរួម ហើយព្រមទាំងមុខងាររបស់គេក្នុងសង្គម ។ ចំពោះមេដឹកនាំជាប្រភេទមនុស្ស ដែលមានលទ្ធភាពគ្រប់គ្រាន់ ហើយនឹងឥទ្ធិពលយ៉ាងខ្លាំង គ្របដណ្តប់ទៅលើអ្នកដទៃ មិនតែប៉ុណ្ណោះមានសមត្ថភាពក្នុងការរៀបចំសកម្មភាព ការងាររួម ដើម្បីធ្វើឱ្យសំរេចបំណង ដែលបានកំណត់ ។ លើសពីនេះយើងក៏អាចបំភ្លឺ នយោបាយដឹកនាំ - គឺជាប្រភេទ នយោបាយ ដែលបានឆ្លុះបញ្ចាំងបង្ហាញពីទង្វើរបស់មេដឹកនាំឆ្លើយតបទៅនឹងតំរូវការ និង ចំណាប់អារម្មណ៏របស់ប្រជាជន ដោយប្រើកិត្យានុភាព និង ឥទ្ធិពលរបស់ខ្លួន។ ចំណែកឯមេដឹកនាំខ្លះទៀត ស្ម័គ្រចិត្តរំលែកអំណាចមួយផ្នែកឱ្យតំណាង របស់ខ្លួន ដើម្បីសំរេចគោលដៅហើយនឹងផែនការរបស់គេផ្ទាល់ ។

## ជំពូកទី ៩ : ក្រុមសំពាធ រឺ ក្រុមផលប្រយោជន៍ ៣ ម៉ោង

Pressure Groups or Groups interest គឺជាក្រុមមនុស្សដែលមានសកម្មភាពព្យាយាមធ្វើឱ្យសំរេចនូវគោលបំណងរបស់ខ្លួន។ ដោយប្រើគ្រប់មធ្យោបាយធ្វើឱ្យមានឥទ្ធិពលទៅលើគ្រប់រចនាសម្ព័ន្ធ គ្រប់គ្រងរបស់រដ្ឋអំណាច ។

**************

### ឯកសារយោង


1/ Roy C.Macridis, Contemporary Political Ideologies Fourth Edition U.S.A 1989.
2/ James E. Anderson, Public policy making in introduction, Second Edition New York 1984.
3/ Oganesen Anna Armenakova Politology, Moseoue 1999.
4/ Khorashilova A. N History of political-law theories Moscoue 2001.
5/ Ian Adams and R.W.Dyson. Fifty Major Political thinkers U.S.A and Canada 2003
6/ Bladilen Semonovich Serbin, Politology Piatigorsk 1995.
7/ ឈុន ណារ៉េត ទ្រឹស្តីនយោបាយ និងប្រវត្តិគំនិតនយោបាយ ភ្នំពេញ , 2005.
8/ N.A Volgina, Social Politics, Mosoue 2004.


# Course Assessment

| | |
|---|---|
| **- Attendants** | **10%** |
| **- Assignment** | **15%** |
| **- Midterm** | **25%** |
| **- Final Examine** | **50%** |